ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នស/រកម/០៦២២/០០៦

# ច្បាប់
# ស្តីពី
# សុវត្ថិភាពម្ហូបអាហារ

www.moj.gov.kh

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ១០៧
ថ្ងៃ: ... ទី ១០ ខែមិថុនា ឆ្នាំ២០២២
ម៉ោង: ១១:០០នាទី

# ព្រះរាជក្រម

## យើង

នស/រកម/០៦២២/០០៦

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# សុវត្ថិភាពម្ហូបអាហារ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនិងយន្តការសម្រាប់គ្រប់គ្រង និងធានាសុវត្ថិភាព គុណភាព អនាម័យ និងភាពស្របច្បាប់ នៃម្ហូបអាហារ ក្នុងគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ ដើម្បីផ្តល់ការការពារសុខភាពនិងសុវត្ថិភាពម្ហូបអាហារសម្រាប់អ្នកប្រើប្រាស់ និងធានាឱ្យមានការធ្វើពាណិជ្ជកម្មម្ហូបអាហារប្រកបដោយភាពស្មោះត្រង់។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពម្ហូបអាហារ ដែលគ្របដណ្តប់គ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ និងលើអាជីវកម្មម្ហូបអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចដឹកនាំ សម្របសម្រួលការគ្រប់គ្រងគុណភាព សុវត្ថិភាពម្ហូបអាហារ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

## ជំពូកទី៣
## បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ និងគោលការណ៍ត្រួតពិនិត្យ

**មាត្រា៥ .-**

ការរៀបចំបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារត្រូវផ្អែកលើ៖

- ស្តង់ដារកម្ពុជាផ្នែកម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិ
- ស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំអន្តរជាតិ ដែលបានចេញដោយអង្គការសុវត្ថិភាពម្ហូបអាហារអន្តរជាតិនិងថ្នាក់តំបន់ក្នុងករណីស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំកម្ពុជាមិនបានកំណត់
- តម្រូវការជាក់ស្តែង និងត្រូវឆ្លើយតបទៅនឹងស្ថានភាពនៃសុខភាពមនុស្ស ឧស្សាហកម្ម ពាណិជ្ជកម្ម និងស្ថានភាពសេដ្ឋកិច្ចជាតិ។

បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ ត្រូវអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិតាមសំណើរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីក្រុមប្រឹក្សាស្តង់ដារជាតិមិនទាន់មានកំណត់បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ ក្រសួងពាណិជ្ជកម្មត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីកំណត់បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ។

**មាត្រា៦ .-**

ការកំណត់លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដោយត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារដូចមានចែងក្នុងមាត្រា៥ខាងលើ។

ការកំណត់លក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារត្រូវអនុលោមតាមគោលការណ៍ដូចខាងក្រោម៖

(ក) ម្ហូបអាហារត្រូវមានសុវត្ថិភាព គុណភាព និងភាពសមស្របសម្រាប់មនុស្សបរិភោគ។

(ខ) ម្ហូបអាហារមិនត្រូវបាននាំចូល ផលិត កែច្នៃ ឬលក់ ក្នុងលក្ខណៈក្លែងបន្លំឬបំភាន់។

(គ) អ្នកប្រើប្រាស់បានទទួលព័ត៌មានគ្រប់គ្រាន់អំពីម្ហូបអាហារ ដូចជាប្រភពដើម គ្រឿងផ្សំ តម្លៃ អាហារូបត្ថម្ភ និងចំនួនកាឡូរី របៀបប្រើប្រាស់ និងការរក្សាទុក។

(ឃ) ម្ហូបអាហារត្រូវបំពេញតាមលក្ខខណ្ឌអនាម័យ ការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា។

(ង) ម្ហូបអាហារដែលត្រូវបានចាត់ថាជាប្រភេទមានហានិភ័យខ្ពស់ ត្រូវចុះបញ្ជិកាឱ្យបានត្រឹមត្រូវ។

(ច) ការស្តុកទុកឬទីតាំងស្តុកម្ហូបអាហារ ត្រូវបំពេញតាមលក្ខខណ្ឌសម្រាប់ការរក្សាសុវត្ថិភាព និងគុណភាពរបស់ម្ហូបអាហារ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយនូវរាល់ព័ត៌មានថ្មីៗអំពីលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារ។

**មាត្រា៧ ..**

ការត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវធ្វើឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារនៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ តាមតួនាទីនិងភារកិច្ចរៀងៗខ្លួន៖

(ក) ផ្អែកលើលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារដែលនឹងត្រូវកំណត់ស្របតាមមាត្រា៦ខាងលើ ហើយក្នុងករណីចាំបាច់ ត្រូវផ្អែកលើស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំអន្តរជាតិ ដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

(ខ) ផ្អែកលើការសិក្សាវាយតម្លៃហានិភ័យ ដោយឈរលើមូលដ្ឋាននៃភស្តុតាងវិទ្យាសាស្ត្រដែលមាននិងត្រូវបានអនុវត្តក្នុងរបៀបមួយដែលឯករាជ្យ សត្យានុម័ត និងមានតម្លាភាព។

(គ) មានសមាមាត្រចំពោះហានិភ័យនេះ។

(ឃ) មិនតម្រូវឱ្យមានលក្ខណៈតឹងរ៉ឹងជាងភាពចាំបាច់នៃការត្រួតពិនិត្យ។

(ង) មិនត្រូវបង្កើតឧបសគ្គដែលមិនចាំបាច់ដល់ដំណើរការពាណិជ្ជកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ច។

(ច) មិនឱ្យមានការរើសអើងរវាងផលិតផល ឬផលិតករក្នុងស្រុក ឬបរទេស ឬក្នុងចំណោមប្រទេសផ្សេងទៀតនៅពេលដែលមានលក្ខខណ្ឌដូចគ្នាឬប្រហាក់ប្រហែលគ្នា។

**មាត្រា៨ ..**

ក្នុងករណីដែលត្រូវឆ្លើយតបនឹងស្ថានភាពបន្ទាន់នៃសុវត្ថិភាពម្ហូបអាហារ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវចេញបទប្បញ្ញត្តិដាក់កំហិតបន្ថែមលើលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់នោះ។ ការដាក់កំហិតបន្ថែមនោះ ត្រូវមានរយៈពេលកំណត់ជាក់លាក់ និងត្រូវបានពិនិត្យឡើងវិញ ក្នុងកំលុងពេលកំណត់មួយ។ នៅពេលដែលលែងមានស្ថានភាពបន្ទាន់ហើយនោះ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវលុបចោលការដាក់កំហិតបន្ថែមលើលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារនោះវិញ តាមសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៩ ..**

ការប្រកបអាជីវកម្មម្ហូបអាហារ ត្រូវមានលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ រាល់ការចេញលិខិតអនុញ្ញាតត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារ។

រាល់បុគ្គលទាំងឡាយណា ដែលបានប្រកបអាជីវកម្មម្ហូបអាហារ ត្រូវស្ថិតនៅក្រោមនីតិវិធីនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១០ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវកំណត់ក្រុមនៃប្រភេទអាជីវកម្មម្ហូបអាហារ និងត្រូវបង្កើតលក្ខខណ្ឌតម្រូវផ្សេងៗគ្នាដោយផ្អែកលើ៖

(ក) ប្រភេទនៃទីកន្លែងអាជីវកម្ម។

(ខ) ប្រភេទនៃប្រតិបត្តិការអាជីវកម្ម។

(គ) ប្រភេទនៃម្ហូបអាហារ។

ការដាក់ឱ្យអនុវត្តនូវលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារខាងលើ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវរក្សាបញ្ជីនិងធ្វើបច្ចុប្បន្នភាពនៃប្រតិបត្តិករអាជីវកម្មម្ហូបអាហារទាំងអស់ ក្រោយពីបានផ្តល់/ទទួលលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១១ .-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារមានកាតព្វកិច្ចជាចម្បងដូចខាងក្រោម៖

- ត្រូវធានាថាម្ហូបអាហារមានសុវត្ថិភាព គុណភាព និងភាពសមស្របសម្រាប់មនុស្សបរិភោគ ស្របតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ
- ត្រូវដោះស្រាយបញ្ហាសុវត្ថិភាពម្ហូបអាហារនៅពេលដែលកើតមាននៅក្នុងអាជីវកម្មរបស់ខ្លួន
- ត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ
- ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ក្នុងការអនុវត្តវិធានការដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យដែលបានបង្កដោយផលិតផលនៃអាជីវកម្មម្ហូបអាហារដែលពាក់ព័ន្ធ ព្រមទាំងការអង្កេតដាន ការប្រមូលម្ហូបអាហារមកវិញ និងការដកហូតម្ហូបអាហារ។

**មាត្រា១២ .-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ ហើយត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ក្នុងការអនុវត្តវិធានការដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យដែលបានបង្កដោយផលិតផលនៃអាជីវកម្មម្ហូបអាហារដែលពាក់ព័ន្ធ ព្រមទាំងការអង្កេតដាន ការប្រមូលម្ហូបអាហារមកវិញ និងការដកហូតម្ហូបអាហារ។

**មាត្រា១៣ .-**

ផលិតករ អ្នកកែច្នៃ ឬអ្នកវេចខ្ចប់ម្ហូបអាហារដាក់លក់មួយ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ និងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ផលិតករ អ្នកកែច្នៃ ឬអ្នកវេចខ្ចប់ម្ហូបអាហារមិនត្រូវ៖

(ក) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ពុំមានសុវត្ថិភាព។

(ខ) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយបន្លំម៉ាក ឬមិនមានដាក់កាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់ ឬដាក់ស្លាកសញ្ញាមិនអនុលោមតាមលក្ខខណ្ឌស្តីពីស្លាកសញ្ញាដូចមានចែងក្នុងស្តង់ដារកម្ពុជាស្តីពីការដាក់ស្លាកសញ្ញាម្ហូបអាហារវេចខ្ចប់។

(គ) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករនៃម្ហូបអាហារ។

(ឃ) ស្តុកទុក ឬធ្វើសហត្ថាករណ៍ ឬទុកដាក់ ដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា១៤ ៖**

អាជីវករលក់ដុំ និងអាជីវករចែកចាយ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្នុងប្រតិបត្តិការអាជីវកម្មលក់ដុំ និងអាជីវកម្មចែកចាយ អាជីវករលក់ដុំ ឬអាជីវករចែកចាយមិនត្រូវ៖

(ក) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារ ក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ខ) រក្សាទុក លក់ដុំ ឬចែកចាយម្ហូបអាហារ ដែលផ្ទុយនឹងសេចក្ដីណែនាំអំពីសុវត្ថិភាពរបស់ផលិតករ។

(គ) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារពុំមានសុវត្ថិភាព ឬបន្លំម៉ាក។

(ឃ) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារ ដែលមិនអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករនៃម្ហូបអាហារ។

(ង) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារ ដោយដឹងថាពុំមានសុវត្ថិភាព។

(ច) រក្សាទុក ឬធ្វើសហគ្គាករណ៍ ឬទុកដាក់ ដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា១៥ ៖**

អាជីវករលក់រាយ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្នុងប្រតិបត្តិការអាជីវកម្មលក់រាយ អាជីវករលក់រាយ មិនត្រូវ៖

(ក) ដាក់លក់ម្ហូបអាហារ ក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ខ) ធ្វើសហគ្គាករណ៍ ឬទុកដាក់ម្ហូបអាហារក្នុងស្ថានភាពគ្មានអនាម័យ។

(គ) ដាក់ស្លាកសញ្ញាគ្រប់ប្រភេទពុំត្រឹមត្រូវ។

(ឃ) ដាក់លក់ម្ហូបអាហារ ដែលមិនអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករ និង/ឬអ្នកចែកចាយនៃម្ហូបអាហារ។

(ង) លក់ម្ហូបអាហារ ដោយដឹងថាពុំមានសុវត្ថិភាព ឬបន្លំម៉ាក។

**មាត្រា១៦ ៖**

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ មានសិទ្ធិធ្វើការអង្កេតដាន និងដកហូតម្ហូបអាហារមកវិញ តាមប្រភេទអាជីវកម្មម្ហូបអាហារ ដែលប៉ះពាល់ដល់សុខភាពមនុស្ស៖

(ក) តាមដានថយក្រោយមួយដំណាក់ម្ដងៗពីបុគ្គលដែលផ្គត់ផ្គង់សាច់សត្វ ឬវត្ថុធាតុដើមផ្សេងៗទៀត និងសារធាតុផ្សំ សម្រាប់ផលិតម្ហូបអាហារ ឬសារធាតុដែលនឹងប្រើសម្រាប់ ឬរំពឹងថានឹងត្រូវដាក់បញ្ចូលទៅក្នុងម្ហូបអាហារ។

(ខ) តាមដានទៅមុខមួយដំណាក់ម្ដងៗលើអ្នកទិញដែលជាអ្នកផ្សេង ក្រៅពីអ្នកប្រើប្រាស់ចុងក្រោយ។

(គ) កំណត់អត្តសញ្ញាណនៃឡូត៍នៅកន្លែងទទួល នៅកន្លែងផលិតម្ហូបអាហារ ឬបរិមាណនៃម្ហូបអាហារដែលផលិតចេញពីសាច់សត្វ ឬវត្ថុធាតុដើម និងសារធាតុផ្សំផ្សេងៗទៀតដែលត្រូវបានដាក់បញ្ចូលក្នុងម្ហូបអាហារ ឬបញ្ជូនមកកន្លែងផលិត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតដាន និងការដកហូតម្ហូបអាហារ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៧ ៖**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវអនុវត្តតាមលក្ខខណ្ឌអនាម័យម្ហូបអាហារដែលបានកំណត់ក្នុងលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារ និង/ឬក្នុងសេចក្ដីសម្រេចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារព្រមទាំងបទប្បញ្ញត្តិផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអនាម័យម្ហូបអាហារ។

**មាត្រា១៨.-**

រាល់ម្ហូបអាហារដែលវេចខ្ចប់ស្រេចសម្រាប់លក់ ត្រូវមានស្លាកសញ្ញា ដូចបានកំណត់ក្នុងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារនិងក្នុងសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ព្រមទាំងបទប្បញ្ញត្តិផ្សេងៗទៀតដែលពាក់ព័ន្ធនឹងស្លាកសញ្ញាដូចមានចែងក្នុងស្តង់ដារកម្ពុជាស្តីពីការដាក់ស្លាកសញ្ញាម្ហូបអាហារវេចខ្ចប់។

រាល់ស្លាកសញ្ញាទាំងនោះត្រូវៈ

(ក) មានព័ត៌មានដែលអាចអង្កេតឃើញបាន។

(ខ) សរសេរជាភាសាខ្មែរ យ៉ាងហោចណាស់ចំពោះចំណុចដែលពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ និងកិច្ចការការពារអ្នកប្រើប្រាស់ ហើយនៅពេលដែលស្លាកសញ្ញាដើមមិនមែនជាភាសាខ្មែរ អាចប្រើប្រាស់ស្លាកសញ្ញាភាសាខ្មែរបន្ថែមពីលើជំនួសឱ្យការដាក់ស្លាកសញ្ញាសាជាថ្មី។

(គ) កំណត់ពីព័ត៌មានពិស្តារ ដែលអាចត្រូវបានបញ្ញត្តិ ដោយរួមមាននូវព័ត៌មានពីអាហាររូបត្ថម្ភ។

(ឃ) មិនមានព័ត៌មាន ឬរូបភាពណាមួយ ដែលផ្ទុយពីព័ត៌មាននៅលើស្លាកសញ្ញា ឬលក្ខខណ្ឌតម្រូវស្តីពីស្លាកសញ្ញាណាមួយដែលបានបញ្ញត្តិ ឬមិនត្រូវធ្វើឱ្យយល់ខុស ឬក្លែងបន្លំអ្នកប្រើប្រាស់នៅក្នុងលក្ខណៈណាមួយនោះទេ។

(ង) អាចអានបាន ឬមិនត្រូវបាំងដោយវត្ថុវេចខ្ចប់ខាងក្រៅប្រសិនបើមាន។

បែបបទនិងលក្ខខណ្ឌនៃការដាក់ស្លាកសញ្ញា ត្រូវកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា១៩.-**

ត្រូវហាមឃាត់រាល់ការផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ ទោះតាមទម្រង់ណាក៏ដោយ ដែលមានលក្ខណៈភូតកុហកពង្វាងការពិត ឬការអះអាងណាមួយដែលមិនពិត ការក្លែងបន្លំ ឬការធ្វើឱ្យមានការភាន់ច្រឡំអំពីលក្ខណៈពិតនៃគុណភាពនិងសុវត្ថិភាពម្ហូបអាហារដូចជាៈ

(ក) ការរំពឹងទុកនៃផលិតផល។

(ខ) អត្តសញ្ញាណ ប្រភេទ យថាប្រភេទ ប្រភព លក្ខណៈ រូបរាង ឬអាហាររូបត្ថម្ភ។

(គ) គុណភាព ធាតុផ្សំ បរិមាណ របៀបនៃការកែច្នៃផលិត និងកាលបរិច្ឆេទនៃការផលិត។

(ឃ) កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ វិធីណែនាំ និងលក្ខខណ្ឌនៃការប្រើប្រាស់។

(ង) វិធីសាស្ត្រនៃការលក់ ការអាចរកទិញបាននៃផលិតផល និងតម្លៃ។

(ច) ការធានាអះអាងផ្សេងៗដែលលើសពីភាពពិត។

ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ កំណត់អំពីលក្ខខណ្ឌតម្រូវសម្រាប់ការផ្សាយពាណិជ្ជកម្មផលិតផលម្ហូបអាហារ។

**មាត្រា២០.-**

ក្រសួងពាណិជ្ជកម្ម ត្រូវបង្កើតឱ្យមានប្រព័ន្ធឆ្លើយតបដល់សាធារណជន ពាក់ព័ន្ធនឹងបញ្ហាគុណភាព សុវត្ថិភាពម្ហូបអាហារ ការដាក់ស្លាកសញ្ញាម្ហូបអាហារ ឬបណ្តឹងនានាពាក់ព័ន្ធនឹងអាជីវកម្មម្ហូបអាហារ ឬបញ្ហាសុវត្ថិភាពម្ហូបអាហារដទៃទៀតនៅលើទីផ្សារ។

**មាត្រា២១.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវរៀបចំឱ្យមានលក្ខណៈវិនិច្ឆ័យនៃមន្ទីរពិសោធន៍យោងនិងមន្ទីរពិសោធន៍ផ្លូវការ ដើម្បីធ្វើការវិភាគ ស្របតាមគោលបំណងនៃច្បាប់នេះ។

លក្ខណៈវិនិច្ឆ័យនៃមន្ទីរពិសោធន៍យោងនិងមន្ទីរពិសោធន៍ផ្លូវការ ត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី៤
# ការធ្វើអធិការកិច្ចម្ហូបអាហារ

**មាត្រា២២ ..**

ការធ្វើអធិការកិច្ចម្ហូបអាហារ ត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចម្ហូបអាហាររបស់ក្រសួងពាណិជ្ជកម្មនិង/ឬដោយមន្ត្រីអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ទៅតាមដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្ម តាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ដើម្បីលើកកម្ពស់គុណភាពនិងសុវត្ថិភាពម្ហូបអាហារ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារត្រូវៈ

(ក) បង្កើតប្រព័ន្ធអធិការកិច្ចម្ហូបអាហារ ដោយផ្អែកលើមូលដ្ឋាននៃការសិក្សាវាយតម្លៃហានិភ័យ។

(ខ) កំណត់ប្រព័ន្ធចំណាត់ថ្នាក់ហានិភ័យសម្រាប់អាជីវកម្មម្ហូបអាហារ និងកំណត់ប្រភេទអាជីវកម្មដាក់លាក់នៅក្រោមប្រព័ន្ធចំណាត់ថ្នាក់នោះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចម្ហូបអាហារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា២៣ ..**

មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចម្ហូបអាហារនៃក្រសួងពាណិជ្ជកម្ម ឬមន្ត្រីអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា២៤ ..**

មន្ត្រីអធិការកិច្ចម្ហូបអាហារដូចមានចែងក្នុងមាត្រា២២នៃច្បាប់នេះ ដែលត្រូវចុះបំពេញភារកិច្ចក្នុងបរិវេណនិងក្នុងទីតាំងធ្វើអាជីវកម្មម្ហូបអាហារ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងមានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង/ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៥ ..**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវរក្សាព័ត៌មានដែលបានរកឃើញក្នុងកំលុងពេលនៃការធ្វើអធិការកិច្ចជាការសម្ងាត់ លើកលែងតែមានការអនុញ្ញាតពីប្រធានស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ឬតុលាការតម្រូវឱ្យលាតត្រដាងព័ត៌មាននោះ។

# ជំពូកទី៥
# ម្ហូបអាហារនាំចូល

**មាត្រា២៦ ..**

ការនាំចូលម្ហូបអាហារ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដូចមានចែងក្នុងច្បាប់នេះ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ការនាំចូលម្ហូបអាហារអាចតម្រូវឱ្យមានភ្ជាប់វិញ្ញាបនបត្រដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ ស្របទៅតាមគោលការណ៍គ្រប់គ្រងហានិភ័យដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

បញ្ជីទំនិញម្ហូបអាហារដែលជាកម្មវត្ថុសម្រាប់តម្រូវការឯកសារ និងលក្ខខណ្ឌនៃការនាំចូល ត្រូវកំណត់ដោយ

**មាត្រា២៧.-**

ក្នុងករណីចាំបាច់ដែលម្ហូបអាហារនាំចូលតម្រូវឱ្យមានការធ្វើវិភាគ ដើម្បីផ្ទៀងផ្ទាត់ភាពអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ សំណាកគំរូ ត្រូវយកមកធ្វើការវិភាគដោយមន្ទីរពិសោធន៍ជំនាញដូចមានចែងក្នុងមាត្រា២១នៃច្បាប់នេះ។

**មាត្រា២៨.-**

ម្ហូបអាហារនាំចូលដែលមិនអនុលោមតាមច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ត្រូវសម្រេចចាត់ចែងដូចខាងក្រោម៖

(ក) តម្រូវឱ្យនាំចេញទៅវិញ។

(ខ) តម្រូវឱ្យកែច្នៃសាជាថ្មី រួមទាំងការដាក់ស្លាកសញ្ញាជាថ្មី និងបញ្ជូនទៅធ្វើការត្រួតពិនិត្យជាផ្លូវការម្តងទៀត។

(គ) កម្ទេចចោល។

រាល់ការចំណាយពាក់ព័ន្ធជាបន្ទុករបស់អ្នកនាំចូល។

## ជំពូកទី៦
## ម្ហូបអាហារដែលចរាចរនៅលើទីផ្សារ

**មាត្រា២៩.-**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវធ្វើការត្រួតពិនិត្យនិងអង្កេតនៅតាមទីផ្សារ ចំពោះផលិតផលដែលមានហានិភ័យខ្ពស់និងចំពោះផលិតផលដែលទទួលបានព័ត៌មានថាមានហានិភ័យ ដោយផ្អែកលើមូលដ្ឋានព័ត៌មានដែលបញ្ជាក់អំពីហានិភ័យ ហើយត្រូវសមាមាត្រទៅនឹងកម្រិតហានិភ័យដែលមានក្នុងម្ហូបអាហារនោះ។

ក្នុងករណីចាំបាច់ មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវយកគំរូនៅតាមទីផ្សារមកវិភាគនៅមន្ទីរពិសោធន៍ និងធ្វើការកត់ត្រាអំពីលទ្ធផល និងមានវិធានការតាមនីតិវិធីបន្ត។

**មាត្រា៣០.-**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវសម្រេចចាត់ចែងចំពោះម្ហូបអាហារនៅលើទីផ្សារដែលមិនអនុលោមតាមលក្ខខណ្ឌតម្រូវនានាដែលបានបញ្ញត្តិក្នុងច្បាប់ និងក្នុងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងនឹងម្ហូបអាហារ ដូចខាងក្រោម៖

(ក) ឱ្យធ្វើការកែតម្រូវឡើងវិញ។

(ខ) តម្រូវឱ្យកែច្នៃសាជាថ្មី។

(គ) រឹបអូសនិងកម្ទេចចោល ក្នុងករណីដែលមិនអាចកែតម្រូវឬកែច្នៃសាជាថ្មីបាន។

រាល់ការចំណាយពាក់ព័ន្ធជាបន្ទុករបស់ម្ចាស់ម្ហូបអាហារ។

## ជំពូកទី៧
## ម្ហូបអាហារនាំចេញ

**មាត្រា៣១.-**

ការនាំចេញម្ហូបអាហារ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនានារបស់ប្រទេសនាំចូលស្របតាមកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី៨
## កម្រៃសេវា

**មាត្រា៣២.-**

កម្រៃសេវា ដែលស្ថិតក្រោមក្របខ័ណ្ឌនៃការអនុវត្តច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងដែលទទួលបន្ទុកពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS

# ជំពូកទី៩
# ទោសប្បញ្ញត្តិ

**មាត្រា៣៣ .-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមាន ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មព្រហ្មទណ្ឌ។

ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរ ឬដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ
- ការបិទអាជីវកម្ម។

ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងការបិទអាជីវកម្ម ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារដែលចេញលិខិតអនុញ្ញាតទាំងនោះ និង/ឬស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចម្ហូបអាហារ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចម្ហូបអាហារមានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រមូលប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៤ .-**

ត្រូវពិន័យអន្តរការណ៍ពី៥០០ ០០០(ហាសិបម៉ឺន)រៀលទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

(ក) ដំណើរការអាជីវកម្មម្ហូបអាហារ ដោយមិនមានលិខិតអនុញ្ញាត។

(ខ) រៀបចំ ស្តុកទុក ធ្វើសហគ្គការណ៍ ឬលក់ម្ហូបអាហារ ដែលខ្វះអនាម័យ។

(គ) មិនបានជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ។

(ឃ) មិនបានបង្កើត និងអនុវត្តប្រព័ន្ធដែលអាចអង្កេតដាន ដែលបានកំណត់ក្នុងច្បាប់នេះ។

(ង) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករ និង/ឬអ្នកចែកចាយម្ហូបអាហារ។

(ច) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារដែលមិនមានដាក់កាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ឆ) ផ្គត់ផ្គង់ លក់ដុំ ចែកចាយ ឬដាក់លក់ម្ហូបអាហារក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ជ) មិនបានគោរពតាមវិធានអនាម័យ ដែលត្រូវកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

(ឈ) មិនបានផ្ដល់ព័ត៌មានអំពីខ្លឹមសារដែលបញ្ជាក់ពីគុណភាព សុវត្ថិភាពនៃម្ហូបអាហារ ដែលនឹងត្រូវផ្សាយដំណឹងពាណិជ្ជកម្ម។

(ញ) មិនបានគោរពតាមការណែនាំនិងការកែតម្រូវរបស់មន្ត្រីអធិការកិច្ចម្ហូបអាហារ។

ក្នុងករណីទទួលនូវការពិន័យអន្តរការណ៍ម្ដងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា៣៤នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៥ ._**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារនៃរោងចក្រនិងសហគ្រាសធុនតូចនិងមធ្យម ដែលផ្គត់ផ្គង់ លក់ដុំ ចែកចាយ ឬដាក់លក់ម្ហូបអាហារក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

**មាត្រា៣៦ ._**

ត្រូវពិន័យអន្តរការណ៍ពី២ ០០០ ០០០(ពីរលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារដែលបញ្ញត្តិក្នុងមាត្រា៦នៃច្បាប់នេះ។

ក្នុងករណីទទួលរងការពិន័យអន្តរការណ៍ម្ដងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា៣៦នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៧ ._**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលផ្សាយពាណិជ្ជកម្ម ឬធ្វើឱ្យមានការផ្សាយពាណិជ្ជកម្មដែលមិនពិត ឬធ្វើឱ្យយល់ខុស ឬធ្វើឱ្យមានការភាន់ច្រឡំអំពីលក្ខណៈពិតនៃម្ហូបអាហារ ត្រូវពិន័យអន្តរការណ៍ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល។

ក្នុងករណីទទួលនូវការពិន័យអន្តរការណ៍ម្ដងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា៣៧ នៃច្បាប់នេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រា៣៧នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៨ ._**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារដែលដាក់ស្លាកសញ្ញាម្ហូបអាហារដែលមានលក្ខណៈមិនពិត ធ្វើឱ្យយល់ខុស ឬក្លែងបន្លំ អំពីលក្ខណៈពិតនៃម្ហូបអាហារ ត្រូវពិន័យអន្តរការណ៍ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

ក្នុងករណីទទួលនូវការពិន័យអន្តរការណ៍ម្ដងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា៣៨ នៃច្បាប់នេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រា៣៨នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៩ .-**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២០០ ០០០ ០០០(ពីររយលាន)រៀលទៅ៤០០ ០០០ ០០០(បួនរយលាន)រៀល ចំពោះអំពើផលិត កែច្នៃ វេចខ្ចប់ ចែកចាយ ឬលក់ម្ហូបអាហារដោយដឹងថាម្ហូបអាហារនោះមានផ្ទុកនូវសារជាតុពុល ឬសារជាតុបង្កគ្រោះថ្នាក់ដែលលើសកម្រិតអនុញ្ញាត ដែលនាំឱ្យខូចសុខភាពដល់មនុស្ស។

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត កាលបើអំពើនោះបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងសុវត្ថិភាពអ្នកប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ។

ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌផ្សេងទៀត កាលបើអំពើនោះបង្កឱ្យមានពិការភាពអចិន្ត្រៃយ៍ ឬបាត់បង់អាយុជីវិតរបស់អ្នកប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ។

**មាត្រា៤០ .-**

នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានក្នុងមាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសបន្ថែមណាមួយឬច្រើនដូចតទៅ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា១៧៤(ការហាមឃាត់ចំពោះការធ្វើការអំពាវនាវជាសាធារណៈឱ្យសន្សំសំចៃ)នៃក្រមព្រហ្មទណ្ឌ។

៦- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទដែលកំណត់ដោយមាត្រា១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹបអូសនិងសិទ្ធិតតិយជន)នៃក្រមព្រហ្មទណ្ឌ។

៧- ការរឹបអូសផលទុននិងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទដែលកំណត់ដោយមាត្រា១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹបអូសនិងសិទ្ធិតតិយជន)នៃក្រមព្រហ្មទណ្ឌ។

៨- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីផ្តន្ទាទោស)នៃក្រមព្រហ្មទណ្ឌ។

៩- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៤១ .-**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្ដាលឱ្យប៉ះពាល់ដល់សិទ្ធិ បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលបានប្រព្រឹត្តសកម្មភាពណាមួយដូចខាងក្រោម៖

(ក) រឹបអូសម្ហូបអាហារដោយមូលហេតុណាមួយ ក្រៅពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់នេះ។

(ខ) លាតត្រដាងព័ត៌មានណាមួយ ដែលបានទទួលក្នុងពេលបំពេញភារកិច្ចរបស់ខ្លួនក្រោមច្បាប់នេះ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ឬត្រូវបានតម្រូវដោយតុលាការឱ្យលាតត្រដាងព័ត៌មានពាក់ព័ន្ធនោះ ឬមានការអនុញ្ញាតដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តជាធរមានដោយឡែក។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា៤២ .-**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាព និងភាពសមស្របនៃម្ហូបអាហារហើយដែលមិនផ្ទុយនឹងច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៤៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ ព្រហ ៩កើត ខែ ពិស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០២២

នស/រកម.០៦២២.០២៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
# សទ្ទានុក្រម

១. **ការកែច្នៃ** សំដៅដល់សកម្មភាពណាមួយដែលបម្លែងឬផ្លាស់ប្តូរទម្រង់ដើមនៃផលិតផល។

២. **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់ការបង្ហាញនានា ជាលាយលក្ខណ៍អក្សរ រូបភាព តាមមធ្យោបាយសោតទស្សន៍ ឬតាមមធ្យោបាយផ្សេងទៀត ដែលធ្វើឡើងដើម្បីផ្សព្វផ្សាយលើកកម្ពស់ដោយផ្ទាល់ឬប្រយោលនូវការលក់ ការផ្តល់សេវាម្ហូបអាហារ ឬសារធាតុណាមួយដែលចាត់ទុកថាជាម្ហូបអាហារ។

៣. **ការសិក្សាវាយតម្លៃហានិភ័យ** សំដៅដល់ការវាយតម្លៃលើផលប៉ះពាល់ដល់សុខភាពតាមបែបវិទ្យាសាស្ត្រដែលបណ្តាលមកពីភ្នាក់ងារបង្កគ្រោះជីវសាស្ត្រ គីមីសាស្ត្រ និងរូបវន្ត ដោយចែកចេញជាបួនជំហានរួមមាន៖

- ១. ការកំណត់អត្តសញ្ញាណភ្នាក់ងារបង្កគ្រោះ។
- ២. ការកំណត់ចរិតលក្ខណៈភ្នាក់ងារបង្កគ្រោះ។
- ៣. ការវាយតម្លៃអំពីផលរងទទួល។
- ៤. ការកំណត់ចរិតលក្ខណៈហានិភ័យ។

៤. **ការវេចខ្ចប់** សំដៅដល់សកម្មភាពវេចខ្ចប់ម្ហូបអាហារស្របតាមលក្ខខណ្ឌតម្រូវនានា ដើម្បីធានាគុណភាពសុវត្ថិភាពរបស់ផលិតផលម្ហូបអាហារចុងក្រោយសម្រាប់អ្នកប្រើប្រាស់។

៥. **ខ្សែចង្វាក់ម្ហូបអាហារ** សំដៅដល់រាល់ដំណាក់កាលទាំងអស់របស់ផលិតកម្មម្ហូបអាហារ ដោយរាប់ចាប់ពីការផលិតដំបូង រហូតដល់ការចាត់ចែង និងការលក់ម្ហូបអាហារ ដំណាក់កាលរាប់ចាប់ពីកសិដ្ឋានផលិតដល់កន្លែងបរិភោគ។

៦. **ភាពសមស្របនៃម្ហូបអាហារ** សំដៅដល់ម្ហូបអាហារដែលមានលក្ខណៈធម្មជាតិ មានអនាម័យ មានសុវត្ថិភាព និងមិនមានលាយសារធាតុមិនសុទ្ធ។

៧. **ទីកន្លែងអាជីវកម្មម្ហូបអាហារ** សំដៅដល់អគារ តង់ ឬចនាសម្ព័ន្ធផ្សេងទៀត ទាំងអចិន្ត្រៃយ៍ ទាំងបណ្តោះអាសន្ន ស្ថិតនៅលើដីនិងទីកន្លែងជាប់នោះ ដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតកម្ម ការវេចខ្ចប់ ការដឹកជញ្ជូន ការចាត់ចែង ការបម្រើសេវា ការស្តុកទុក ឬការលក់ម្ហូបអាហារប្រភេទណាមួយ។

៨. **ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ** សំដៅដល់ម្ចាស់អាជីវកម្មម្ហូបអាហារ ឬបុគ្គលដែលត្រូវបានប្រគល់សិទ្ធិក្នុងការប្រតិបត្តិអាជីវកម្មម្ហូបអាហារ ឬបុគ្គលទទួលខុសត្រូវលើអាជីវកម្មម្ហូបអាហារ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដូចជាផលិតករ អ្នកកែច្នៃ អ្នកវេចខ្ចប់ អាជីវករលក់ដុំ អាជីវករចែកចាយ និងអាជីវករលក់រាយ ជាដើម។

៩. **ប្រព្រឹត្តិកម្ម** សំដៅដល់ការដាក់ពណ៌ ការជ្រលក់ពណ៌ ការដាក់ម្សៅ ការខាត់ ការស្រោច ការលាយ ការរក្សាទុក ការដាក់រសជាតិ ការពង្រាវ ការធ្វើឱ្យខាប់ជាមួយនឹងសារធាតុណាមួយ ការកម្តៅ ឬការសម្លាប់មេរោគ។

១០. **ការអង្កេតដាន** សំដៅដល់សកម្មភាពតាមរកដាននៃការចល័តនៃម្ហូបអាហារ តាមដំណាក់កាលជាក់លាក់នៃផលិតកម្ម ការកែច្នៃ និងការចែកចាយ។

១១. **សារធាតុបង្កគ្រោះថ្នាក់** សំដៅដល់សារធាតុគីមីដែលត្រូវបានប្រើលើសកម្រិតអនុញ្ញាតនៃបទដ្ឋានជាតិ អន្តរជាតិ មានសក្តានុពលបង្កផលប៉ះពាល់អវិជ្ជមានដល់សុខភាព។

១២. **មន្ត្រីអធិការកិច្ចម្ហូបអាហារ** សំដៅដល់មន្ត្រីដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ដែលត្រូវបានចាត់តាំងស្របតាមមាត្រា២៣នៃច្បាប់នេះ។

១៣- **ម្ហូបអាហារ** សំដៅដល់ផលិតផលឬសារធាតុណាមួយ ទោះបីត្រូវកែច្នៃទាំងស្រុង ឬពាក់កណ្តាលកែច្នៃឬ មិនទាន់កែច្នៃ សម្រាប់មនុស្សបរិភោគ រួមទាំងភេសជ្ជៈ ស្ករកៅស៊ូ និងសារធាតុទាំងឡាយ ដែលត្រូវបានប្រើប្រាស់ នៅក្នុងផលិតកម្ម ការរៀបចំ ឬការធ្វើប្រព្រឹត្តិកម្មនៃម្ហូបអាហារ លើកលែងតែគ្រឿងសម្អាង ផលិតផលថ្នាំជក់ ឬផលិតផលដែលប្រើប្រាស់សម្រាប់ឱសថ។

១៤- **ម្ហូបអាហារលក់តាមផ្លូវ** សំដៅដល់ម្ហូបអាហាររៀបចំរួចជាស្រេចឬរៀបចំភ្លាមៗ សម្រាប់ដាក់លក់នៅ តាមផ្លូវ ទីផ្សារ និងនៅតាមទីកន្លែងសាធារណៈផ្សេងៗ។

១៥- **យាន** សំដៅដល់គ្រប់មធ្យោបាយដែលប្រើប្រាស់សម្រាប់ដឹកជញ្ជូនម្ហូបអាហារពីកន្លែងមួយទៅកន្លែងមួយ ទៀត។

១៦- **លក់** សំដៅដល់សកម្មភាព ដូចជាស្នើលក់ ផ្សាយដំណឹងពាណិជ្ជកម្ម រក្សាទុក ស្តុកទុក ដាក់បង្ហាញ បញ្ជូន ផ្ញើទុក ផ្ទេរ ឬប្រគល់ឱ្យ សម្រាប់លក់ ផ្លាស់ប្តូរ ឬចាត់ចែងទៅឱ្យបុគ្គលណាម្នាក់ដើម្បីតម្លៃតបស្នងណាមួយ ឬ ផ្សេងពីនេះ។

១៧- **លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ** សំដៅដល់លក្ខណវិនិច្ឆ័យ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងគុណភាព សុវត្ថិភាពម្ហូបអាហារដែលមានលក្ខណៈដាច់ខាតត្រូវបំពេញ។

១៨- **វិញ្ញាបនបត្រកម្ម** សំដៅដល់នីតិវិធីដែលអង្គភាពវិញ្ញាបនបត្រកម្មផ្លូវការ និងអង្គភាពដែលត្រូវបានទទួល ស្គាល់ជាផ្លូវការ ផ្តល់ការធានាជាលាយលក្ខណ៍អក្សរ ឬការធានាដែលមានតម្លៃសមមូលថាផលិតផល ម្ហូបអាហារឬ ប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារណាមួយ អនុលោមតាមលក្ខខណ្ឌតម្រូវ។

១៩- **វិញ្ញាបនបត្រ** សំដៅដល់ឯកសារភ្ជាប់ជាមួយនឹងម្ហូបអាហារ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដូចជា វិញ្ញាបនបត្រសុវត្ថិភាពម្ហូបអាហារ វិញ្ញាបនបត្របសុព្យាបាល វិញ្ញាបនបត្រភូតគាមអនាម័យ វិញ្ញាបនបត្រ វិភាគ ឬឯកសារផ្សេងទៀតដោយអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ។

២០- **សារធាតុ** សំដៅដល់វត្ថុធាតុរឹង រាវ ឬឧស្ម័ន។

២១- **សារធាតុបន្ថែម** សំដៅដល់សារធាតុដែលជាទូទៅមិនអាចបរិភោគបានជាម្ហូបអាហារនិងជាធម្មតាមិនត្រូវ បានប្រើប្រាស់ជាគ្រឿងផ្សំសម្រាប់ផលិតម្ហូបអាហារ ទោះបីជាសារធាតុបន្ថែមនោះមានឬមិនមានតម្លៃជា អាហារូបត្ថម្ភក្តី។ សារធាតុបន្ថែមទាំងនោះ ត្រូវបានគេប្រើប្រាស់ដោយចេតនាទៅក្នុងម្ហូបអាហារ ក្នុងគោលបំណង បច្ចេកវិទ្យា នៅក្នុងដំណើរការផលិតកម្ម កម្មន្តសាល ការរៀបចំ ប្រព្រឹត្តិកម្ម ការខ្ចប់ ការវេចខ្ចប់ ការដឹកជញ្ជូន ឬការស្តុកទុកម្ហូបអាហារទាំងនោះ ដើម្បីឱ្យមានលទ្ធផល ឬអាចរំពឹងទុកដោយសមហេតុផលថាមានលទ្ធផល (ដោយផ្ទាល់ឬប្រយោល) នៅក្នុងម្ហូបអាហារ ឬអនុផលរបស់ម្ហូបអាហារនោះ ឱ្យក្លាយទៅជាសមាសភាពរបស់ ម្ហូបអាហារ ឬក៏អាចប៉ះពាល់ដល់ចរិតលក្ខណៈរបស់ម្ហូបអាហារ។ ប៉ុន្តែ សារធាតុបន្ថែមនេះ មិនរួមបញ្ចូលនូវ សារធាតុចម្លង ឬជាសារធាតុដែលបន្ថែមក្នុងម្ហូបអាហារដើម្បីរក្សាឬបង្កើនគុណភាពអាហារូបត្ថម្ភនោះទេ។

២២- **សុវត្ថិភាពម្ហូបអាហារ** សំដៅដល់ការអនុវត្តដំណើរការធានាថា ម្ហូបអាហារមិនបង្កគ្រោះថ្នាក់ដល់អ្នក ប្រើប្រាស់នៅពេលដែលត្រូវបានយកទៅធ្វើការរៀបចំ ឬបរិភោគស្របតាមកម្មវត្ថុប្រើប្រាស់របស់ម្ហូបអាហារនោះ។

២៣- **សំបកវេចខ្ចប់** សំដៅដល់វត្ថុនានាដែលសម្រាប់ដាក់ឬវេចម្ហូបអាហារមួយផ្នែកឬទាំងមូល និងកន្ត្រក ភាជន៍ ប្រអប់ ថាស ឬវត្ថុសម្រាប់ដាក់ផ្សេងទៀត ទោះមានឬមិនមានគម្របក្តី។

២៤- **ស្តង់ដារម្ហូបអាហារ** សំដៅដល់ស្តង់ដារផលិតផលជាក់លាក់និងស្តង់ដារទូទៅ ដោយរួមបញ្ចូលផងដែរនូវក្រម ប្រតិបត្តិ គោលការណ៍ណែនាំ។ ស្តង់ដារម្ហូបអាហារនេះ អនុវត្តចំពោះម្ហូបអាហារទាំងអស់ ទោះត្រូវបានកែច្នៃ រួចហើយ ឬពាក់កណ្តាល ឬនៅស្រស់ ឆៅ សម្រាប់ចែកចាយដល់អ្នកប្រើប្រាស់។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

២៥. **ស្ថានភាពគ្មានអនាម័យ** សំដៅដល់លក្ខខណ្ឌឬកាលៈទេសៈដែលអាចបង្កឱ្យមានការឆ្លង ឬនាំឱ្យមានការប៉ះពាល់ឬគ្រោះថ្នាក់ដល់សុខភាពរបស់អ្នកប្រើប្រាស់។

២៦. **ស្លាកសញ្ញា** សំដៅដល់ស្លាក យីហោ ម៉ាក ជារូបភាព ឬជាការពិពណ៌នាជាលាយលក្ខណ៍អក្សរ ជាការបោះពុម្ព ការបោះពុម្ពដោយប្រើស្ពិនស៊ីល ការគូសសម្គាល់ ធ្វើឱ្យក្រឡោត ឬរលេចនៅលើ ឬភ្ជាប់ទៅនឹងវត្ថុសម្រាប់ដាក់ ឬសំបកវេចខ្ចប់ម្ហូបអាហារ។

២៧. **អ្នកនាំចេញ** សំដៅដល់បុគ្គលដែលជាកម្មសិទ្ធិករ អ្នកផ្ញើទំនិញ អ្នកទទួលទំនិញ ភ្នាក់ងារ ឬឈ្មួញកណ្ដាលដែលមានកម្មសិទ្ធិ ឬទទួលបានសិទ្ធិតាមវិធីណាមួយ ក្នុងការរក្សាទុក ឬមើលខុសត្រូវលើម្ហូបអាហារដែលនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

២៨. **អ្នកនាំចូល** សំដៅដល់បុគ្គលណាមួយ រួមមានអ្នកដែលជាកម្មសិទ្ធិករ អ្នកផ្ញើទំនិញ អ្នកទទួលទំនិញ ភ្នាក់ងារ ឬឈ្មួញកណ្ដាល ដែលមានកម្មសិទ្ធិ ឬទទួលបានសិទ្ធិតាមវិធីណាមួយក្នុងការរក្សាទុក ឬមើលខុសត្រូវលើម្ហូបអាហារ ដែលនឹងត្រូវនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

២៩. **អាជីវកម្មម្ហូបអាហារ** សំដៅដល់សកម្មភាពធុរកិច្ចណាមួយដែលមិនមែនជាការធ្វើអាជីវកម្មម្ហូបអាហារ លក់តាមផ្លូវ ទោះជាខ្នាតតូចក្ដី ដែលត្រូវធ្វើប្រតិបត្តិការនៅកន្លែងផលិតកម្ម កម្មន្តសាល ការរៀបចំ ប្រព្រឹត្តិកម្ម ការខ្ចប់ ការវេចខ្ចប់ ការដឹកជញ្ជូន ការលើកដាក់ ការបម្រើសេវា ការស្តុកទុក ឬការលក់ពាក់ព័ន្ធនឹងម្ហូបអាហារ ទោះក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ឬមិនស្វែងរកប្រាក់ចំណេញ។

៣០. **សហគ្រាសម្ហូបអាហារ** សំដៅដល់សកម្មភាពណាមួយដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការរៀបចំ ការរក្សាទុក និងការបម្រើសេវាម្ហូបអាហារនៅក្នុងទីតាំងម្ហូបអាហារ។

៣១. **បទប្បញ្ញត្តិបច្ចេកទេស** សំដៅដល់ឯកសារដែលចែងអំពីចរិតលក្ខណៈផលិតផលឬដំណើរការពាក់ព័ន្ធ និងវិធីសាស្ត្រផលិតកម្ម ដោយរួមបញ្ចូលទាំងបញ្ញត្តិរដ្ឋបាលដែលអាចអនុវត្តបាន ដែលការអនុលោមមានលក្ខណៈបញ្ជា។ បទប្បញ្ញត្តិបច្ចេកទេស អាចរួមបញ្ចូលឬប្រើប្រាស់សម្រាប់តែការតម្រូវផ្នែក វាក្យសព្ទ និមិត្តសញ្ញា ការវេចខ្ចប់ ការធ្វើសញ្ញាសម្គាល់ ឬការធ្វើស្លាកសញ្ញា ដែលអនុវត្តទៅលើផលិតផល ដំណើរការ ឬវិធីសាស្ត្រផលិតកម្ម។

៣២. **អនាម័យម្ហូបអាហារ** សំដៅដល់លក្ខខណ្ឌនិងវិធានការទាំងអស់ដែលចាំបាច់ធានាសុវត្ថិភាព និងភាពសមស្របនៃម្ហូបអាហារ នៅគ្រប់ដំណាក់កាលទាំងអស់នៃខ្សែចង្វាក់ម្ហូបអាហារ។

៣៣. **មន្ទីរពិសោធន៍ផ្លូវការ** សំដៅដល់មន្ទីរពិសោធន៍ដែលធ្វើតេស្តលើផលិតផលអាហារ គ្រឿងផ្សំ គំរូសំណាកកែច្នៃ និងគំរូសំណាកបរិស្ថានដែលពាក់ព័ន្ធសម្រាប់ការវិភាគកេប៉ារ៉ាម៉ែត្រ រូបសាស្ត្រ គីមី និងមីក្រូជីវសាស្ត្រ ហើយសំដៅដល់មន្ទីរពិសោធន៍រដ្ឋ ដែលគ្រប់គ្រងដោយក្រសួងឬស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវបានកំណត់លើមុខងារនិងវិសាលភាពជាក់លាក់។

៣៤. **មន្ទីរពិសោធន៍យោង** សំដៅដល់មន្ទីរពិសោធន៍ដែលធ្វើតេស្តលើផលិតផលអាហារ គ្រឿងផ្សំ គំរូសំណាកកែច្នៃ និងគំរូសំណាកបរិស្ថានដែលពាក់ព័ន្ធសម្រាប់ការវិភាគកេប៉ារ៉ាម៉ែត្រ រូបសាស្ត្រ គីមី និងមីក្រូជីវសាស្ត្រ ហើយសំដៅដល់មន្ទីរពិសោធន៍រដ្ឋឬឯកជនដែលមានជំនាញឯកទេសវិភាគតាមវិសាលភាពដែលត្រូវបានកំណត់ជាក់លាក់និងទទួលបានការវាយតម្លៃពីស្ថាប័នទទួលស្គាល់។

៣៥. **ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ** សំដៅដល់ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងទេសចរណ៍ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *